# ព័ត៌មានសំខាន់ៗទាក់ទងនឹងការផ្លាស់ប្តូរបណ្តោះអាសន្នពីសាលា Edwin Forrest ទៅ អនុវិទ្យាល័យ Austin Meehan

ការចុះឈ្មោះសិស្សកាន់តែមានការកើនឡើងជាបន្ត ហើយអស់រយៈពេលជាច្រើនឆ្នាំកន្លងមកនេះ យើងគ្មានសមត្ថភាពទទួលសិស្សទូទាំងតំបន់ជិតខាងនៃវិទ្យាល័យ Lincoln រួមទាំងសាលា Forrest ផងដែរ។ ដោយមូលហេតុនេះ ក្នុងឆ្នាំ ២០១៧ ក្រសួងអប់រំបានចាប់ផ្តើមអនុវត្តយុទ្ធសាស្ត្រទូលំទូលាយមួយដើម្បីកាត់បន្ថយនូវចំនួនដែលកាន់តែកើនឡើង និងមានសិស្សលើសចំនួននេះ ហើយពង្រីកសាលាឱ្យត្រូវតាមសេចក្តីត្រូវការនៅក្នុងតំបន់។ សមាសភាគសំខាន់ៗនៃយុទ្ធសាស្ត្រនេះ រួមមាន ប៉ុន្តែមិនមែនមានតែប៉ុណ្ណឹងទេ៖

1) ការបើកសាលា Northeast Community Propel Academy ដែលជាសាលាថ្មីសម្រាប់ ថ្នាក់មត្តេយ្យ ដល់ ថ្នាក់ទី៨ ក្នុងឆ្នាំសិក្សា ២០២១-២០២២
2) ការកាត់សាលា Forrest ទៅជា ថ្នាក់មត្តេយ្យ ដល់ ថ្នាក់ទី៥ ក្នុងឆ្នាំសិក្សា ២០២១-២០២២
3) ការពង្រីកសាលា Pollock និង Holme ទៅជា ថ្នាក់មត្តេយ្យ ដល់ ថ្នាក់ទី៧ ក្នុងឆ្នាំសិក្សា ២០២១-២០២២ និង ថ្នាក់មត្តេយ្យ ដល់ ថ្នាក់ទី៨ ក្នុងឆ្នាំសិក្សា ២០២២-២០២៣
4) ការកាត់ចេញ និងការបិទអនុវិទ្យាល័យ Meehan នៅចុងបញ្ចប់នៃឆ្នាំសិក្សា ២០២១-២០២២ និង
5) ការបន្តប្រើប្រាស់អគារ Meehan ជាកន្លែងបណ្តោះអាសន្នសម្រាប់សាលាដែលកំពុងជួសជុល ឬសាងសង់ធំៗ

សាលា Forrest ក៏នឹងទទួលការកែលម្អជាច្រើនផងដែរ ដោយសារតែការផ្លាស់ប្តូរទាំងនេះ បានជំរុញឱ្យមានការផ្លាស់ប្តូរសិស្សសាលានេះមួយចំនួនទៅអគារ Meehan សម្រាប់ឆ្នាំសិក្សា ២០២២-២០២៣។

## តើថ្ងៃចាប់ផ្តើម និងថ្ងៃបញ្ចប់នៃទីតាំងបណ្តោះអាសន្ននៅថ្ងៃណាខ្លះ?

ការផ្លាស់ទីកន្លែងបានកំណត់ថានឹងចាប់ផ្តើមនៅថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០២២ (ថ្ងៃចូលរៀនដំបូងសម្រាប់សិស្ស) ហើយនឹងបញ្ចប់នៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០២៣ (ថ្ងៃរៀនចុងក្រោយសម្រាប់សិស្ស)។

## ហេតុអ្វីបានជាការផ្លាស់ទីកន្លែងបណ្តោះអាសន្ននេះជាការចាំបាច់?

ការផ្លាស់ទីកន្លែងបណ្តោះអាសន្នគឺជាការចាំបាច់ដើម្បីផ្តល់បរិយាកាសអប់រំល្អបំផុតសម្រាប់សិស្ស ក្នុងអំឡុងពេលជួសជុលយ៉ាងច្រើននៅសាលា Forrest។ ហើយក៏នឹងអនុញ្ញាតឱ្យមានការវិលត្រឡប់ទៅសាលា Forrest ដែលបានធ្វើរួចវិញយ៉ាងលឿនផងដែរ។

## តើទីតាំងដែលត្រូវផ្លាស់ប្តូរបណ្តោះអាសន្នត្រូវបានកំណត់យ៉ាងដូចម្តេច?

កត្តាជាច្រើនត្រូវបានពិចារណានៅពេលជ្រើសរើសទីតាំងដែលត្រូវផ្លាស់ប្តូរទៅ ដែលល្អបំផុតសម្រាប់សាលាណាមួយ រួមមាន៖

- ***ចម្ងាយពីសាលាបច្ចុប្បន្ន*** - យើងចង់កាត់បន្ថយពេលវេលាធ្វើដំណើរបន្ថែមសម្រាប់សិស្ស ក្រុមគ្រួសារ និងបុគ្គលិក។
- ***ទំហំនៃទីកន្លែងដែលនៅទំនេរ*** - នៅពេលណាអាចធ្វើទៅបាន យើងចង់ឱ្យសិស្សក្នុងសាលាទាំងមូលនៅជាមួយគ្នា នៅកន្លែងផ្លាស់ប្តូរទៅតែមួយ។ ការឃើញមុខសិស្ស និងបុគ្គលិកដែលធ្លាប់ស្គាល់គ្នាច្រើន ជួយបង្កើតបទពិសោធន៍ដែលមិនផ្លាស់ប្តូរសម្រាប់សិស្ស។ យើងក៏ចង់បានសាលាមានកន្លែងដែលមិនប្រើ ដើម្បីកុំឱ្យយើងរំខានដល់ប្រតិបត្តិការសាលាដែលទទួលយើង។
- ***ប្រភេទនៃកន្លែងទំនេរ*** - អាហារដ្ឋាន បន្ទប់ទឹកសម្រាប់សិស្ស និងបុគ្គលិក និងចំនួនបន្ទប់ដែលចាំបាច់ គឺជាតម្រូវការសំខាន់ៗមួយចំនួនដែលត្រូវតែមានតាមការចង់បាន។
- ***ទ្វារចូល និងទ្វារចេញ ដាច់ដោយឡែក*** - ការមានទ្វារចូល និងទ្វារចេញ ដាច់ដោយឡែក មានសារៈសំខាន់ណាស់ក្នុងការធ្វើឱ្យប្រតិបត្តិការសាលាមានសុវត្ថិភាព និងមានសណ្តាប់ធ្នាប់ ជាពិសេសនៅពេលដែលសាលាមានទីតាំងរួមគ្នា ជាមួយសាលាផ្សេងទៀត។
- ***ការអាចប្រើប្រាស់បាន*** - សមត្ថភាពក្នុងការរៀបចំកន្លែងបានឆាប់រហ័សសម្រាប់ការចូលមក និងបញ្ជូនសិស្សទៅកាន់បរិយាកាសសិក្សា។

## ហេតុអ្វីបានជាអនុវិទ្យាល័យ Austin Meehan ត្រូវបានជ្រើសរើសជាកន្លែងផ្លាស់ប្តូរបណ្តោះអាសន្នសម្រាប់សាលា Edwin Forrest?

អនុវិទ្យាល័យ Austin Meehan គឺជាជម្រើសដ៏ល្អបំផុត ដោយសារ៖

- នៅជិត - ក្នុងចម្ងាយ ២ ម៉ាយ ពីសាលា Edwin Forrest
- ធ្លាប់បានប្រើជាកន្លែងបណ្តោះអាសន្នពីមុនដោយជោគជ័យ ហើយមានថ្នាក់រៀនដែលមិនប្រើនៅដាច់ដោយឡែក ក្នុងអគារ

- អាចដាក់សិស្សសាលា Edwin Forrest ទាំងអស់បាន សិស្សថ្នាក់ទី២ ដល់ ថ្នាក់ទី៥ សិស្សថ្នាក់មត្តេយ្យ ដល់ ថ្នាក់ទី១ នឹងបន្តនៅ មណ្ឌលអប់រំបឋមសិក្សា (Primary Education Center) ដែលស្ថិតនៅ Forrest School Main Campus នៅអាស័យដ្ឋាន 7300 Walker Street
- មានអាហារដ្ឋានដែលមានអ្វីៗគ្រប់យ៉ាង និងបន្ទប់ទឹកឯកជន និង
- មានទ្វារដាច់ដោយឡែកសម្រាប់កចូល និងចេញ ពីសាលា Edwin Forrest

**តើការប្រុងប្រយ័ត្នអ្វីខ្លះដែលត្រូវបានចាត់វិធានការដើម្បីធានាសុវត្ថិភាព និងសុខុមាលភាពរបស់សិស្សសាលា Forrest ក្នុងអំឡុងពេលផ្លាស់ប្តូរទីតាំងនេះ?**

**កន្លែងដាក់សិស្សសាលា Edwin Forrest គឺជាកន្លែងដាច់ដោយឡែកក្នុងអគារ។ ដូច្នេះ សិស្សសាលា Pollock និង Forrest នឹងមិនអាចទាក់ទងគ្នាបានទេ។ សន្តិសុខសាលាបន្ថែម ត្រូវបានបន្ថែមនៅសាលា Austin Meehan ដើម្បីសម្រួលដល់ការផ្លាស់ប្តូរទីតាំងបណ្តោះអាសន្ននៃ សាលា Pollock និង Forrest។**

**<u>យកសិស្សមកសាលា Meehan នៅពេលព្រឹក</u>**

មកដល់នៅម៉ោង ៧:៣០ ព្រឹក
ចេញនៅម៉ោង ២:០៩ រសៀល

រថយន្តសាលានឹងទៅដឹកសិស្សនៅកន្លែងដែលត្រូវឈប់ក្នុងសហគមន៍ នៅចន្លោះម៉ោង ៦:៤៥ ព្រឹក និង ៧:០០ ព្រឹក។ រថយន្តសាលានឹងមកដល់សាលា Meehan នៅម៉ោង ៧:១៥ ព្រឹក។

រថយន្តសាលាឈប់នៅផ្លូវដូចមានខាងក្រោមនេះ៖

- Sheffield & Walker,
- Sheffield & Torresdale,
- Bleigh & Torresdale,
- Bleigh & Erdrick,
- Walker & Wellington
- Friendship & Edmund

**<u>នៅពេលរថយន្តសាលាមកដល់សាលា Meehan នៅពេលព្រឹក</u>**

- រថយន្តសាលានឹងចូលចតនៅផ្លូវចូលសាលាដាច់ដោយឡែក ហើយសមាជិកបុគ្គលិក ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា នឹងនាំសិស្សដោយផ្ទាល់ទៅកាន់កន្លែងឯកជនដែលនៅដាច់

ដោយឡែក ក្នុងអគារ។

**<u>ការអនុវត្តក្នុងអំឡុងថ្ងៃសិក្សា</u>**

- ការបង្ហាត់បង្រៀននឹងប្រព្រឹត្តិទៅនៅក្នុងថ្នាក់រៀនដែលបានចាត់តាំងសម្រាប់សិស្ស Forrest ។
- សិស្សនឹងញ៉ាំអាហារពេលព្រឹក និងអាហារថ្ងៃត្រង់ នៅក្នុងអាហារដ្ឋានឯកជនសម្រាប់តែសិស្ស Forrest ប៉ុណ្ណោះ។
- សិស្សនឹងមានសិទ្ធិចូលប្រើបន្ទប់ទឹកឯកជនក្នុងអំឡុងថ្ងៃរៀន។
- បុគ្គលិក Forrest នឹងត្រួតពិនិត្យតាមរបៀងសាលា និងបន្ទប់ទឹក ដើម្បីធានាសុវត្ថិភាព និងភាពសុខស្រួលរបស់សិស្សនៅកន្លែងថ្មី។

**<u>ជិះរថយន្តពីសាលា Meehan នៅពេលរសៀល</u>**

- រថយន្តសាលានឹងត្រឡប់មកកន្លែងដាក់សិស្សចុះពេលព្រឹកវិញ ដែលនៅដាច់ដោយឡែក។
- នៅម៉ោង ២:០៩ រសៀល បុគ្គលិករបស់ Forrest នឹងនាំសិស្សចេញពីអាគារ ហើយចាប់ផ្តើមនាំពួកគេឡើងជិះរថយន្តសាលាដោយសុវត្ថិភាព។
- **សំខាន់៖** យើងនឹងជូនដំណឹងដល់ មាតាបិតា/អាណាព្យាបាល នៅម៉ោង ២:២៤ រសៀល។ (១៥ នាទី ក្រោយពេលចេញពីរៀន) ហើយរំលឹកពួកគាត់ឱ្យមកយកកូនពី **Meehan**។

**<u>អាហារថ្ងៃត្រង់</u>**

- នាយកសាលានឹងផ្តល់កាលវិភាគអាហារថ្ងៃត្រង់ដោយប្រើអាហារដ្ឋានដែលមានស្រាប់។ **Meehan** មានផ្ទះបាយដែលមានសម្ភារៈគ្រប់គ្រាន់។